## វិធានការការពារ:

- ត្រូវប្រញាប់រាយការណ៍ជូនមន្ត្រីបសុពេទ្យ ឬ ភ្នាក់ងារសុខភាពសត្វភូមិដែលនៅជិតអ្នកបំផុត នៅពេលសត្វមានឆ្លងជំងឺអុតក្តាម
- ត្រូវបំបែកសត្វឈឺចេញពីហ្វូង
- ត្រូវធ្វើអនាម័យកន្លែងចិញ្ចឹមជាប្រចាំ
- ត្រូវផ្តល់ចំណីអាហារទន់ៗ
- ត្រូវលាងសំអាតរបួសដោយទឹកម្ជូរ
- ត្រូវលាបមុខរបួសដោយថ្នាំប្ញីមេទីឡែន
- ហាមចលនាសត្វចេញ-ចូល ឬ ឆ្លងកាត់តំបន់ផ្ទុះជំងឺ
- ហាមទិញ-លក់សត្វគ្រប់ប្រភេទ ដែលមានជំងឺ ឬផ្ទុកមេរោគ

វិធានការដែលមានប្រសិទ្ធភាព ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺអុតក្តាមគឺ ការចាក់ថ្នាំការពារ (ចាក់វ៉ាក់សាំង) ជាមុន។ ការចាក់វ៉ាក់សាំងការពារជាមុន មិនត្រឹមតែអាចការពារសត្វមិនឱ្យកើតជំងឺអុតក្តាមប៉ុណ្ណោះទេ តែថែមទាំងផ្តល់អត្ថប្រយោជន៍ជាច្រើនទៀតដូចជា:

- សត្វមិនឈឺ និង មិនឆ្លងជំងឺពីសត្វដទៃទោះបីសត្វនោះស្ថិតនៅកន្លែងផ្ទុះជំងឺក្តី
- សត្វគ្មានជំងឺ និង មានសុខភាពល្អ
- ថ្នាំការពារ(វ៉ាក់សាំង) មានតម្លៃថោក
- កាត់បន្ថយការចំណាយថវិកាក្នុងការព្យាបាល
- បង្កើនប្រាក់ចំណូល

ដូចនេះ ដើម្បីការពារសត្វកុំឱ្យកើតជំងឺអុតក្តាម ត្រូវចាក់វ៉ាក់សាំងការពារសត្វឱ្យបានទៀងទាត់តាមប្រតិទិនចាក់ថ្នាំការពារ។

វ៉ាក់សាំងការពារជំងឺអុតក្តាម ផ្តល់ភាពស៊ាំដែលអាចស្ថេរបានក្នុងរយៈពេល ១០-១២ ខែ។




ថ្នាំសំរាប់ចាក់ការពារជំងឺអុតក្តាម

### កំណត់ចំណាំ:

ចាក់វ៉ាក់សាំងមួយមុខ គឺអាចការពារជំងឺបានតែមួយមុខប៉ុណ្ណោះ។

## ការការពារប្រសើរជាងការព្យាបាល

**នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល**

# អត្ថប្រយោជន៍នៃការចាក់ថ្នាំការពារជំងឺអុតក្តាម

*Foot and Mounth Disease*



**រៀបចំដោយ** : នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល
**អាសយដ្ឋាន** : ផ្លូវ សឡា ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
**ទូរស័ព្ទបន្ទាន់លេខ** : ០១២ ២១៤ ៩៧០
០១២ ៨៣៣ ៧៩៥

## តើជំងឺអុតក្តាមជាអ្វី ?

ជំងឺអុតក្តាម ជាជំងឺឆ្លងដែលកើតមានលើចំពោះសត្វដែលមានចង្វែកជើងពីរដូចជា: គោ ក្របី ជ្រូកពពែ ចៀម.......។ ជំងឺនេះមានកើតឡើងនៅ ពាសពេញពិភពលោក ធ្វើឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កម្លាំងអូសទាញ សេដ្ឋកិច្ចគ្រួសារ និង សេដ្ឋកិច្ចជាតិ ។

## ការចម្លង និងការរាលដាល:

ជំងឺអុតក្តាម ឆ្លងពីសត្វមួយ ទៅសត្វមួយទៀត តាមរយ:ការប៉ះពាល់ជាមួយសត្វឈឺ មនុស្ស ឬ សម្ភារ: ប្រើប្រាស់ដែលប្រឡាក់ប្រឡូសដោយមេរោគ ។ មេរោគនៃជំងឺអុតក្តាម អាចហើរតាមខ្យល់ និង ហូរតាមទឹក ។ ជំងឺអាចកើតឡើងតាមរយ:

- ការប្រើប្រាស់ខោអាវ ស្បែកជើង ឬ សម្ភារ:ប្រើប្រាស់ដែលប្រឡាក់ប្រឡូសមេរោគទៅប៉ះពាល់ជាមួយនឹងសត្វ
- ការផ្តល់ចំណី និង ទឹកដែលប្រឡាក់ប្រឡូសមេរោគ
- ការដឹកនាំសត្វ ដោយមធ្យោយដឹកជញ្ជូន ដែលប្រឡាក់ប្រឡូសមេរោគ
- ការនាំសត្វដែលមានផ្ទុកមេរោគចូលមកក្នុងហ្វូង
- ការដាក់សត្វនៅកន្លែងដែលមានផ្ទុះជំងឺ ។

## រោគសញ្ញា:

រយ:ពេលមេរោគសម្ងំមានពី ១៨ ម៉ោងទៅ ០៣ សប្តាហ៍ ។ រោគសញ្ញាដែលឃើញមាននៅពេលផ្ទុះជំងឺរួមមាន:

- សត្វមានអាការ:គ្រុនក្តៅ ជាពិសេសចំពោះសត្វជំទង់ៗ សីតុណ្ហភាពថយចុះមកវិញនៅ ៤៨ ម៉ោងក្រោយ
- ពងដោរ និង ដំបៅនៅលើមាត់ អណ្តាត បបូរមាត់ បណ្តាលឱ្យមានការហៀរទឹកមាត់ស្អិតអន្លាយ មានបែកពពុះមាត់ មានហូរទឹកមាត់យ៉ាងច្រើន និង ពិបាកស៊ីចំណី ។





- ពងដោរ និងដំបៅនៅចុងដោះ ចន្លោះចង្វែកជើង និង គល់ក្រចកដែលធ្វើឱ្យសត្វពិបាកឈរ និងធ្វើចលនា
- ពងបែកហូរទឹករងៃថ្លា ឬខាប់ និង បន្សល់នូវស្នាម របួសនៅកន្លែងមានពងបែកនោះ
- ការរលូតកូនកើតមានជាញឹកញាប់
- ជំងឺអុតក្តាមកម្របណ្តាលឱ្យសត្វស្លាប់ណាស់ ប៉ុន្តែការធំធាត់ឡើងវិញក្រោយពីសត្វឈឺមានការយឺតយ៉ាវ
- ការស្លាប់អាចកើតមានចំពោះកូនសត្វ ដែលទើបនឹងកើត និងជួនកាលក៏អាចកើតមានដល់សត្វចាស់ផងដែរ ។





